សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ

UNIVERSITY OF PUTHISASTRA

# Maternal Health Nursing1

Presented by: Mrs. Ngim HENG, BSN, RM, NMCHC

Tel: 012 649 251

Email: hengngim@yahoo.com


LEADERSHIP
VS
MANAGEMENT

# ភាពដឹកនាំ និងគ្រប់គ្រងទី២

| ចំណងជើងមេរៀន | ម៉ោង |
|---|---|
| ១. ភាពជាអ្នកដឹកនាំ | ៣ម៉ោង |
| ២. ភាពជំរុញលើកទឹកចិត្ត | ៤ម៉ោង |
| Mid-term | |
| ៣. ការគ្រប់គ្រងទំនាស់ | ៣ម៉ោង |
| ៤. ការវិភាគពីរចនាសម្ពន្ធ័ និងគ្រឹះស្ថានព្យាបាល | ៥ម៉ោង |




# ភាពដឹកនាំ និងគ្រប់គ្រងទី២

បង្ហាញដោយលោកស្រី ហេង ងីម
BSN, RM, NMCHC, MOH

មេរៀនទី១:

# ភាពជាអ្នកដឹកនាំ

# ចក្ខុបំណាច

នៅចុងបញ្ចប់នៃមេរៀននេះ និស្សិតទាំងអស់នឹងអាច៖

1.កំណត់ន័យអ្នកដឹកនាំ

2.ពន្យល់ពីភាពខុសគ្នារវាងអ្នកដឹកនាំនិងអ្នកគ្រប់គ្រង

3.រៀបរាប់ពីចរិកលក្ខណៈ និងលក្ខណៈនៃអ្នកដឹកនាំ

4.រៀបរាប់ពីមុខងារគន្លឹះ និងភារកិច្ចជាមូលដ្ឋាននៃអ្នកដឹកនាំល្អ

# សេចក្តីផ្តើម

នៅក្នុងអង្គភាពណាក៏ដោយគឺត្រូវមានអ្នកដឹកនាំ ព្រោះអ្នកដឹកនាំមានសារៈសំខាន់ណាស់។ បើគ្មានអ្នកដឹកនាំទេគឺ៖

១. អាចគ្មានទិសដៅដើម្បីឈានទៅដល់គោលដៅរបស់អង្គភាពឡើយ

២. អាចគ្មានអ្នកធ្វើផែនការ

៣. មិនអាចអនុវត្តអោយបានត្រឹមត្រូវនូវសកម្មភាពផ្សេងៗ

៤. មិនអាចមានភាពច្បាស់លាស់អំពីតំលៃគោលដៅ និងវត្ថុបំណង

# និយមន័យ អ្នកដឹកនាំ

- អ្នកដឹកនាំ គឺជាមនុស្សម្នាក់ដែលមានសមត្ថភាព មានឥទ្ធិពល ឬជំរុញឱ្យមានអ្នកឯទៀតធ្វើតាមខ្លួន។

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង

អ្នកដឹកនាំ៖

•ជំរុញច្រានរបៀបប្រតិបត្តិការអោយរីកចម្រើន ដោយណែនាំទិសដៅក្នុងការកែប្រែ ឬផ្លាស់ប្តូរ

•ធ្វើការប្រជុំដោយត្រិះរិះពិចារណា

•កំណត់គោលដៅប្រកបដោយមហិច្ឆតាគិតទៅអនាគត

អ្នកគ្រប់គ្រង៖

•ការពាររបៀបប្រតិបត្តិការ ដោយរក្សាតាមប្រព័ន្ធបច្ចុប្បន្ន

•កាត់បន្ថយការប្រជុំប្រថាន

•កំណត់គោលដៅសមស្រប

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- គិតទៅអនាគតកាល និងបង្កើតទស្សនៈវិស័យសម្រាប់អនាគតកាល
- ខិតខំបង្កើតអោយមានបរិយាកាសការងារគួរអោយរំភើបចិត្ត

អ្នកគ្រប់គ្រង៖

- គិតអំពីកង្វល់ចំពោះមុខ និងខ្វល់ខ្វាយក្នុងប្រតិបត្តិការប្រចាំថ្ងៃ
- ខិតខំ ដើម្បីអោយមានបរិយាកាសការងារងាយស្រួល

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- គិតគូពីការបង្កើតថ្មី
- គិតគូរដល់ការច្នៃប្រឌិត
- ផ្ទេរអំណាចដល់អ្នកដទៃ
  - -មានជំនឿលើបុគ្គលិក
  - -ស្វែងរកអ្នកដែលអាចក្លាយជាអ្នកដឹកនាំ
  - -ជំរុញបុគ្គលិកឱ្យកាន់តែខិតខំប្រឹងប្រែងក្នុងការងារ
  - - អ្នកធ្វើការងារទុកដូចជាអ្នកអនុវត្តតាម
  - - មានជំនឿលើក្រុមការងារ

អ្នកគ្រប់គ្រង៖

- គិតគូរដល់ការទទួលខុសត្រូវប្រចាំថ្ងៃ
- ផ្ទេរអំណាចអោយអ្នកដទៃដោយប្រុងប្រយ័ត្ន
  - -អ្នកធ្វើការជានិយោជិក
  - -ជឿជាក់លើប្រព័ន្ធ (រចនាសម្ព័នចាត់តាំង និងដំណើរការការងារ)

# ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង (ត)

អ្នកដឹកនាំ៖

- ប្រើអំណាចដោយស្វាហាប់
- ជំរុញទឹកចិត្តអ្នកក្រោមឱវាទអោយធ្វើសកម្មភាព

អ្នកគ្រប់គ្រង៖

- ប្រើអំណាចដោយប្រុងប្រយ័ត្ន និងធ្វើប្រតិបត្តិការក្នុងរង្វង់ឋានុក្រម
- ត្រួតពិនិត្យអ្នកក្រោមឱវាទ


LET'S DO IT!
GO AND DO IT!
LEADER VS. MANAGER

# ចរិតលក្ខណៈ និងលក្ខណៈពិសេសនៃអ្នកដឹកនាំ

អ្នកស្រាវជ្រាវខ្លះបានសាកល្បងកំណត់ន័យ កិច្ចដឹកនាំទៅតាមលក្ខណៈពិសេសនិងចរិតលក្ខណៈ។ វិធីអោយនិយមន័យកិច្ចដឹកនាំនេះត្រូវបានសម្គាល់ថាជា «មហាបុរស» ឬជាទ្រឹស្តីអំពីលក្ខណៈពិសេសក្នុងសង្គម និងជួនកាលជាចរិតលក្ខណៈនិងលក្ខណៈនៃរូបកាយ។ គេអាចធ្វើចំណាត់ថ្នាក់ដោយផ្អែកលើជំនាញនិងសមត្ថភាព

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ

- ស្លូតបូត ឬសុភាពរាបសារ
- មានសមត្ថភាព
- ស្វ័យត្រួតពិនិត្យ ឬម្ចាស់ការលើខ្លួនឯង
- ជាអ្នករៀបចំចាត់ចែង (មានជំនាញខាងធ្វើផែនការ និងចាត់ចែង)

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (៣)

- ក្លាហាន
- បង្កើតគំនិតថ្មី និងជំរុញចិត្ត (សមត្ថភាពក្នុងការដឹកនាំក្រុមការងារ និងសមត្ថភាពជំរុញទឹកចិត្តខ្លួនឯង និងអ្នកដទៃ)
- មានប្រាជ្ញា (សមត្ថភាពធ្វើអោយការងារមាន ប្រសិទ្ធភាព)

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- មានចិត្តសប្បុរស
- អាកប្បកិរិយាល្អ
- អាចដោះស្រាយបញ្ហាបាន (ប្រាជ្ញាមោះមុត)
- ហ៊ានធ្វើពលិកម្ម
- ធ្វើការងារលំបាក

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- ប្រមើលមើលទៅមុខក្នុងការងារ
- គំនិតទូលំទូលាយ
- មានប្រឌិតញាណ
- មានគំនិតទ្រទ្រង់
- ភាពចាស់ទុំ

# ចរិតលក្ខណៈនៃអ្នកដឹកនាំល្អ (ត)

- មានគំនិតប្ដេជ្ញាអនុវត្ត
- ស្មោះត្រង់
- មានគតិបណ្ឌិត (យល់ដឹង)
- ពូកែចងចាំ
- អ្នកពូកែស្ដាប់

# លក្ខណៈពិសេសនៃបុគ្គលលក្ខណៈ

- យល់ដឹងច្រើនជាងអ្នកក្រោមបង្គាប់
- សម្បូរថាមពលខាងផ្លូវកាយ
- មានសេចក្ដីសាទរ
- មានគំនិតផ្ទាល់ខ្លួន
- មានគំនិតផ្ដួចផ្ដើម

# លក្ខណៈពិសេសនៃបុគ្គលលក្ខណៈ (៣)

- ធ្វើការលំបាក
- សំរេចចិត្តលឿន និងត្រឹមត្រូវ
- មានភាពជាក់លាក់ មានជំហរច្បាស់លាស់
- ស្ងិតស្ងាង តស៊ូ

# លក្ខណៈពិសេសក្លូនសន្តម

- បុិនប្រសប់ ( មិនធ្វើអោយគេអាម៉ាស់ )
- មានសណ្តានចិត្ត
- កិត្យានុភាព
- អំណត់
- ជឿជាក់លើអ្នកដទៃ និងខ្លួនឯង ( ចិត្តភក្តី )
- មិនអួតអាង ( ដាក់ខ្លួន )

# លក្ខណៈនៃរូបកាយ

- មានរូបរាងគួរអោយទាក់ទាញចិត្ត
- នឹងនរ សមរម្យ
- សុខភាពល្អ

# ជំនាញដែលអ្នកដឹកនាំល្អត្រូវមាន

- បញ្ញា មានសមត្ថភាពគិតសមហេតុផល (ជំនាញខាងការគិត)
- បំណិនទទួលរាក់ទាក់ល្អជាមួយអ្នកដទៃ (ជំនាញខាងទំនាក់ទំនងជាមួយមនុស្ស ឬអន្តរបុគ្គល)
- សមត្ថភាពបច្ចេកទេស (ជំនាញបច្ចេកទេស)
- សមត្ថភាពជំរុញទឹកចិត្តផ្ទាល់ខ្លួន និងអ្នកដទៃ (ជំនាញជំរុញទឹកចិត្ត)
- សមត្ថភាពប្រាស្រ័យទាក់ទងយ៉ាងសក្តិសិទ្ធ (ជំនាញប្រាស្រ័យទាក់ទង)
- អារម្មណ៍នឹងនរ និងម្ចាស់ការលើខ្លួនឯង

# ជំនាញដែលអ្នកដឹកនាំល្អត្រូវមាន (ត)

- ជំនាញខាងផែនការកម្ម និងរៀបចំចាត់ចែង
- ប្រាជ្ញាមោះមុត ក្នុងការសម្រេចភារកិច្ច
- បំណិនដឹកនាំក្រុមការងារ
- បំណិនធ្វើអោយការងារមានប្រសិទ្ធភាព
- បំណិនក្នុងការច្នៃប្រឌិត និងកែប្រែថ្មីនៅពេលដែលមានតម្រូវការ
- បំណិនដោះស្រាយភាពតានតឹង។


LEADERSHIP
VS
MANAGEMENT


Thank you!